**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខៈ ១០៣២០ អជ.កបទ.សអ

**សូមជម្រាបមក**
**លោក-លោកស្រី តំណាងអង្គការមិនមែនរដ្ឋាភិបាលបរទេស**
**ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** ៖ ការអញ្ជើញចូលរួមសិក្ខាសាលាស្តីពី *"ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"* សម្រាប់អង្គការមិនមែនរដ្ឋាភិបាលបរទេសនៅកម្ពុជា។

ខ្ញុំសូមជម្រាប លោក-លោកស្រី ថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនឹងរៀបចំសិក្ខាសាលាស្តីពី *"ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"* (ហៅកាត់ថា ច្បាប់ PF) ដែលនឹងប្រព្រឹត្តទៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ចាប់ពីម៉ោង ១៤:០០ ដល់ ១៧:០០ រសៀល ជាភាសាខ្មែរ (បកប្រែជាភាសាអង់គ្លេស) នៅទីស្តីការក្រសួង។

គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងដល់អង្គការមិនមែនរដ្ឋាភិបាលបរទេស អំពីកាតព្វកិច្ច និងនីតិវិធីក្នុងការចូលរួមអនុវត្តច្បាប់ PF ឱ្យមានប្រសិទ្ធភាព និងចូលរួមការពារទប់ស្កាត់រាល់ការប្រព្រឹត្តបទល្មើសពាក់ព័ន្ធនានា។

អាស្រ័យហេតុនេះ សូម លោក-លោកស្រី ចាត់តំណាង **០១រូប** ចូលរួមសិក្ខាសាលាខាងលើ និងធ្វើការចុះឈ្មោះតាមរយៈតំណភ្ជាប់ https://forms.gle/DLTsqod1jVQNhKEP8 ឱ្យបានមុន **ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២**។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់មន្ត្រីទទួលបន្ទុកតាមរយៈទូរស័ព្ទលេខ ០៩៩ ២៧៦ ៥៤៣ ឬ Email: io.dept@mfaic.gov.kh ។

សូមជូនភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

សូម លោក-លោកស្រី ទទួលនូវការរាប់អានពីខ្ញុំ៕

ថ្ងៃព្រហស្បតិ៍ ១កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ញឹម ខេមរា**

<u>សូមបញ្ជាក់ជូនថា៖</u>
- សម្លៀកបំពាក់សមរម្យ

អាសយដ្ឋានៈ លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

## **កម្មវិធី**

សិក្ខាសាលាស្តីពី "ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"

**សម្រាប់អង្គការមិនមែនរដ្ឋាភិបាលបរទេសនៅកម្ពុជា**

**នៅថ្ងៃព្រហស្បតិ៍ ទី០១ ខែធ្នូ ឆ្នាំ២០២២ (រសៀល)**

**នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

------------------

| **ម៉ោង** | | **កម្មវិធី** |
|---|---|---|
| ម៉ោង ១៣:០០ នាទី - ១៤:០០ នាទី | - | ការចុះវត្តមានអ្នកចូលរួម |
| ម៉ោង ១៤:០០ នាទី - ១៤:០៥ នាទី | - | គោរពភ្លេងជាតិ |
| ម៉ោង ១៤:០៥ នាទី - ១៤:២០ នាទី | - | **សន្ទរកថាបើក** |
| | - | ថតរូបអនុស្សាវរីយ៍ |
| ម៉ោង ១៤:៣០ នាទី - ១៥:០០ នាទី | - | បទបង្ហាញស្តីពី "ច្បាប់ និងការអនុវត្តស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ" |
| | - | សំណួរ - ចម្លើយ |
| ម៉ោង ១៥:០០ នាទី - ១៥:៣០ នាទី | - | អាហារសម្រន់ |
| ម៉ោង ១៥:៣០ នាទី - ១៦:០០ នាទី | - | បទបង្ហាញស្តីពី នីតិវិធីស្តីពីការបញ្ជូនដោយមិនបង្អង់នូវសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ |
| | - | សំណួរ - ចម្លើយ |
| ម៉ោង ១៦:០០ នាទី - ១៦:៤៥ នាទី | - | ការបំពេញកម្រងសំណួរ និងបកស្រាយ |
| ម៉ោង ១៥:៤៥ នាទី - ១៧:០០ នាទី | - | **សន្ទរកថាបិទ** |

-------ចប់កម្មវិធី-------

*ក្រសួងការបរទេសរក្សាសិទ្ធិក្នុងកែប្រែកម្មវិធីក្នុងករណីចាំបាច់។